# កម្មវិធីជំនួយ Medi-Cal គ្រប់បែបយ៉ាងសំរាប់មនុស្សពេញវ័យ ដែលមានអាយុ 50 ឡើងទៅ

*ច្បាប់ថ្មីរបស់រដ្ឋកាលីហ្វ័រនីញ៉ា (California) អនុញ្ញាតឲ្យអ្នកស្រុកដែលរស់នៅរដ្ឋ California ទាំងអស់ ដែលមានអាយុចាប់ពី 50 ឆ្នាំឡើងទៅ ដែលមានលក្ខណសម្បត្តិទទួលជំនួយ ដើម្បីទទួលបានកម្មវិធីជំនួយ Medi-Cal គ្រប់បែបយ៉ាងដោយឥតគិតថ្លៃ ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍ទេ!*

## សូមចុះឈ្មោះឥឡូវនេះ!

### តើរដ្ឋាភិបាលនៃរដ្ឋ California ផ្តល់កម្មវិធីជំនួយ Medi-Cal ដែរឬទេ?

*បាទ/ចាំះ។ កម្មវិធី Medi-Cal គឺជាការធានារ៉ាប់រងសុខភាពរបស់រដ្ឋសម្រាប់អ្នកដែលមានប្រាក់ចំណូលទាប។*

### តើកម្មវិធីជំនួយ Medi-Cal នឹងប៉ះពាល់ដល់ស្ថានភាពអន្តោប្រវេសន៍របស់ខ្ញុំ ដែរឬទេ?

*មិនប៉ះពាល់ទេ។ អត្ថប្រយោជន៍ Medi-Cal (លើកលែងតែមន្ទីរថែរក្សាមនុស្សចាស់ជរា ឬស្ថាប័នថែទាំសុខភាពផ្លូវចិត្ត) នឹងមិនប៉ះពាល់ដល់ស្ថានភាពរបស់បុគ្គលណាម្នាក់ឡើយ។ សូមទាក់ទងការិយាល័យកិច្ចការអន្តោប្រវេសន៍របស់ខោនធី L.A. ជាមួយនឹងសំណួរអន្តោប្រវេសន៍របស់អ្នកនៅលេខ: 1-800-593-8222 ឬដោយចូលទៅកាន់គេហទំព័រ: oia.lacounty.gov ។*

### តើខ្ញុំអាចទទួលបានកម្មវិធីជំនួយ Medi-Cal គ្រប់បែបយ៉ាង ដែរឬទេ?

*កម្មវិធីជំនួយ Medi-Cal "គ្រប់បែបយ៉ាង" គឺជាការធានារ៉ាប់រងសុខភាពដែលរ៉ាប់រងលើ៖*

- *ការទៅជួបនឹងវេជ្ជបណ្ឌិត*
- *ការថែរក្សាធ្មេញ*
- *ការថែរក្សា (ភ្នែក)*
- *ការណាត់ជួបនឹងគ្រូពេទ្យឯកទេស*
- *ការថែទាំសុខភាពផ្លូវចិត្ត*
- *សេវាសំរាប់ភាពមិនប្រក្រតីដោយការប្រើប្រាស់សារធាតុគ្រឿងញៀន*
- *ការផ្គត់ផ្គង់ផ្នែកវេជ្ជសាស្ត្រ និងវេជ្ជបញ្ជាទិញថ្នាំពេទ្យ*
- *ការថែទាំក្នុងផ្ទះ*
- *ការដឹកជញ្ជូនទៅតាមការណាត់ជួប*
- *និង មានជាច្រើនទៀត*

### តើខ្ញុំនឹងត្រូវការបង់ប្រាក់ ដែរឬទេ?

*សំរាប់បុគ្គលម្នាក់ៗ និងគ្រួសារភាគច្រើន គឺមិនមានថ្លៃចំណាយទេ។*

### តើខ្ញុំដាក់ពាក្យស្នើសុំកម្មវិធី Medi-Cal បានយ៉ាងដូចម្តេច?

### ទូរស័ព្ទទៅមន្ទីរព្យាបាលរោគក្នុងស្រុករបស់អ្នក

- មន្ទីរព្យាបាលរោគរបស់អ្នក អាចជួយអ្នក ដាក់ពាក្យស្នើសុំកម្មវិធីជំនួយ Medi-Cal ។ អ្នកអាចស្វែងរកមន្ទីរព្យាបាលរោគក្នុងស្រុកសំរាប់ MHLA នៅគេហទំព័រ: dhs.lacounty.gov/mhla ។

### អ្នកក៏អាចទូរស័ព្ទទៅ:

- គំនិតផ្តួចផ្តើមផ្សព្វផ្សាយការថែទាំសុខភាពក្នុងសហគមន៍នៅលេខ (213) 749-4261
- បណ្តាញ BAILA នៅលេខ (888) 624-4752 ឬ គេហទំព័រ BAILAnetwork.org
- LA County DPSS នៅលេខ (866) 613-3777 ឬ គេហទំព័រ Benefitscal.com

### សូមកុំរង់ចាំ។

### ដាក់ពាក្យស្នើសុំកម្មវិធីជំនួយ Medi-Cal នៅថ្ងៃនេះ។